មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ការវិភាគផ្នែកច្បាប់ជុំវិញបទចោទប្រកាន់ និងការកាត់ទោសលើសកម្មជនដីធ្លី អ្នកស្រីយ៉ោម បុប្ផា (ករណីព្រហ្មទណ្ឌលេខ១៥៦០)

## ១.សេចក្តីផ្តើម

កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ អ្នកស្រី យ៉ោម បុប្ផា («ចុងចោទ») ដែលជាសកម្មជនដីធ្លីមកពីសហគមន៍បឹងកក់នៃទីក្រុងភ្នំពេញ ត្រូវបានរកឃើញពិរុទ្ធភាពពីបទ«ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស» តាមមាត្រា ២១៨នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ («ក្រមព្រហ្មទណ្ឌ») ហើយត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន៣ឆ្នាំ។[1] បទចោទប្រកាន់ប្រឆាំងនឹងចុងចោទនេះធ្វើឡើងដោយផ្អែកលើអំណះអំណាងដែលថា អ្នកស្រីបានជាប់ពាក់ព័ន្ធក្នុងការវាយប្រហារលើអ្នករត់ម៉ូតូឌុបពីររូប («ជនរងគ្រោះដើមបណ្តឹង»)កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២។[2]

ចុងចោទ និងប្តីរបស់ចុងចោទគឺ លោក លួស សាខន ត្រូវបានមន្ត្រីប៉ូលីសក្នុងឯកសណ្ឋានស៊ីវិលចាប់ និងឃាត់ខ្លួនកាលវេលាព្រឹកថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២។ ចុងចោទត្រូវបានបញ្ជូនទៅពន្ធនាគារព្រៃសក្លាម២ បន្ទាប់ពីការឃាត់ខ្លួននោះ ដោយឋិតក្រោមការឃុំខ្លួនជាបណ្តោះអាសន្ន។ ដោយឡែក ប្តីរបស់អ្នកស្រីត្រូវបានគេអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញបាន។ ចុងចោទមិនត្រូវបានគេប្រាប់អំពីមូលហេតុដែលឈានដល់ការចាប់ខ្លួន ឬបទល្មើសពាក់ព័ន្ធដល់ការចោទប្រកាន់ឡើយ រហូតទាល់តែចុងចោទបានជួបជាមួយចៅក្រមស៊ើបអង្កេត មួយឬពីរម៉ោងក្រោយបន្ទាប់ពីការចាប់រូបខ្លួនរួចហើយ។ មួយថ្ងៃបន្ទាប់ពីការចាប់ខ្លួនចុងចោទ សកម្មជនដីធ្លីដែលលេចធ្លោមួយរូបទៀត គឺអ្នកស្រី ទឹម សាក់មុន្នី ក៏ត្រូវបានគេចាប់ខ្លួន និងចោទពីបទ«ផ្តល់សេចក្តីប្រកាសដោយភូតកុហក»[3] ដើម្បីទទួលបានទីលំនៅបន្ទាប់ខ្លួនអ្នកស្រីត្រូវបានគេជម្លាសចេញពីផ្ទះនៅបុរីកីឡានៃទីក្រុងភ្នំពេញ។ អ្នកស្រី ទឹម សាក់មុន្នី ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ហើយត្រូវបានគេជំនុំជម្រះក្តីកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ចំថ្ងៃជំនុំជម្រះក្តីរបស់ចុងចោទដែរ។ ទោះជាអ្នកស្រីត្រូវបានគេរកឃើញថាមានកំហុស ការផ្តន្ទាទោសចំពោះអ្នកស្រីគឺត្រូវបានព្យួរ ហើយត្រូវបានគេដោះលែងឲ្យមានសេរីភាពវិញ។[4] ទាំងអ្នកស្រី ទឹម សាក់មុន្នី និងចុងចោទត្រូវបានអង្គការលើកលែងទោសអន្តរជាតិ ផ្តល់នាមថាជាអ្នកទោសមនសិការ ក្នុងអំឡុងពេលជាប់ឃុំបណ្តោះអាសន្ន ហើយមកដល់ពេលនេះ ចុងចោទនៅតែជាអ្នកទោសមនសិការ ដោយសារនៅតែត្រូវបានជាប់ក្នុងពន្ធនាគារ នេះបានតាមការអះអាងរបស់អង្គការលើកលែងទោសអន្តរជាតិ។[5]

---

[1] កំណត់ត្រារបស់អ្នកអង្កេតការណ៍សវនាការរបស់ម.ស.ម.ក។

[2] ដូចខាងលើ។

[3] សាន វ៉ារែល និង ខួច សុភ័ក្រចរិយា «តុលាការត្រូវបានប្រើប្រាស់ជាឧបករណ៍ប្រឆាំងនឹងអ្នកតវ៉ា» កាសែតឌឹភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១២) http://www.phnompenhpost.com/2012090758561/National/courts-tools-in-fight-against-dissent-ngos.html

[4] ម៉ី ទិត្យធារ៉ា ខួច សុភ័ក្រចរិយា និងសាន វ៉ារែល «សកម្មជនដីធ្លីម្នាក់ក្នុងចំណោមពីរនាក់ត្រូវបានដោះលែង» កាសែតឌឹភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២) តាមរយៈ http://www.phnompenhpost.com/2012122760506/National/one-of-two-boeung-kak-land-activists-freed.html

[5] អង្គការលើកលែងទោសអន្តរជាតិ «ការកាត់ទោសសកម្មជននៅកម្ពុជាបង្ហាញពីការធ្លាក់ចុះនៃប្រព័ន្ធតុលាការ»(សារព័ត៌មាន) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ http://www.amnesty.org/en/news/convictions-activists-cambodia-demonstrates-dire-state-justice-2012-12-27

ករណីរបស់ចុងចោទត្រូវបានបើកសវនាការស្របពេលជាមួយនឹងករណីរបស់លោក លួស សាខន និងបងប្អូនប្រុសពីរនាក់របស់ចុងចោទផងដែរ ដែលត្រូវបានគេកាត់ទោសកំបាំងមុខ។ អ្នកទាំងបួនត្រូវបានគេរកឃើញថាមានពិរុទ្ធភាពក្នុងបទចោទប្រកាន់ស្រដៀងគ្នា គឺថា ចុងចោទ និងលោក លួស សាខន ត្រូវបានចោទប្រកាន់ថាបានរៀបផែនការវាយប្រហារ ហើយលោក យ៉ោម កន្លង់ និងលោក យ៉ោម សិដ្ឋ ត្រូវបានចោទប្រកាន់ថាបានធ្វើសកម្មភាពតាមផែនការបញ្ជានោះ។

## ២. សេចក្តីសង្ខេប

ការវិភាគផ្នែកច្បាប់នេះធ្វើឡើងក្នុងគោលបំណង ៖ (១)ផ្តល់ទិដ្ឋភាពអង្គហេតុដែលនាំឲ្យឈានដល់ ការចាប់ខ្លួន ការចោទប្រកាន់ និងការកាត់ទោសដល់ចុងចោទ ព្រមទាំងបទល្មើសចោទប្រកាន់ (២)ធ្វើការវិភាគតាមដំណាក់កាលនៃការចោទប្រកាន់ និងប្រើច្បាប់ទៅតាមអង្គហេតុដែលត្រូវបានគេរាយការណ៍ ហើយនេះបានបង្ហាញឲ្យឃើញថា ច្បាប់ត្រូវបានគេប្រើប្រាស់មិនត្រឹមត្រូវទៅតាមទឡ្ហីករណ៍ដែលប្រមូលបាន (៣)ធ្វើការពិនិត្យលើនិតិវិធីតុលាការ ទាំងដំណាក់កាលមុននិងពេលសវនាការ ហើយរកឃើញថា សិទ្ធិរបស់ចុងចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគេបំពាន តាមវិធីសាស្ត្រសំខាន់ៗជាច្រើន (៤)ផ្តល់ទិដ្ឋភាពសិទ្ធិមនុស្សមូលដ្ឋានដែលត្រូវបានគេមើលរំលងដើម្បីចោទប្រកាន់ ពោលគឺសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិជួបប្រជុំ និងសេរីភាព (ព្រមទាំងសិទ្ធិដែលមិនត្រូវបានចងដោយអំណាចនៃច្បាប់ គឺសិទ្ធិក្នុងការការពារសិទ្ធិមនុស្ស) និង (៥)ធ្វើការសន្និដ្ឋានថាការកាត់ទោសលើចុងចោទ សរឲ្យឃើញនូវការធ្លាក់ចុះយ៉ាងខ្លាំងនៃប្រព័ន្ធយុត្តិធម៌ ហើយតុលាការនៃសាលាឧទ្ធរណ៍គួរតែទម្លាក់ចោលនូវរាល់ការចោទប្រកាន់នានាលើចុងចោទ។

ការវិភាគផ្នែកច្បាប់នេះត្រូវបានតាក់តែងឡើងសម្រាប់ (១)សាលាឧទ្ធរណ៍ដើម្បីជាជំនួយក្នុងការជំនុំជម្រះក្តីនៅសាលាឧទ្ធរណ៍ (២)ចុងចោទ និងមេធាវីរបស់ចុងចោទដើម្បីប្រើប្រាស់ជាឯកសារយោងក្នុងការរៀបចំសំណុំរឿងក្តី និង (៣) ភាគីដទៃទៀតសម្រាប់ប្រើប្រាស់ក្នុងការតស៊ូមតិនានា។ គួរកត់សម្គាល់ផងដែរថា ការវិភាគផ្នែកច្បាប់នេះត្រូវបានធ្វើឡើងដើម្បីឈរជំហរកណ្តាល ដោយធ្វើការវិភាគអង្គហេតុនិងអង្គច្បាប់ដែលពាក់ព័ន្ធ យ៉ាងយកចិត្តទុកដាក់ ស្រដៀងនឹងអ្វីដែលតុលាការគួរធ្វើដូច្នេះដែរ។

ការវិភាគផ្នែកច្បាប់នេះ ត្រូវបានរៀបចំតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

## ៣. អង្គហេតុ

### *ចុងចោទ*

ចុងចោទ ជាស្ត្រីដែលមានវ័យ២៩ឆ្នាំ ហើយជាម្តាយរបស់ក្មេងប្រុសម្នាក់។ ចុងចោទបានប្រឡូកយ៉ាងសកម្មជាមួយសហគមន៍របស់ខ្លួនក្នុងការតវ៉ាប្រឆាំងនឹងការបណ្តេញចេញ ពាក់ព័ន្ធនឹងជីជម្លោះដែលលេចធ្លោក្នុងតំបន់បឹងកក់ដែលបានកើតឡើងកាលពីឆ្នាំ២០០៧។ នៅពេលដែលស្ត្រីសកម្មជន១៣រូប («ស្ត្រីបឹងកក់១៣រូប») ត្រូវបានចាប់ខ្លួន ចោទប្រកាន់ កាត់ទោស និងដាក់ពន្ធនាគារ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ដោយសារតែសកម្មភាពធ្វើបាតុកម្មទាមទារសិទ្ធិដីធ្លីដោយសន្តិវិធីរបស់ពួកគេនោះ ចុងចោទបានឋិតនៅជួរខាងមុខក្នុងការធ្វើយុទ្ធនាការទាមទារឲ្យមានការដោះលែងស្ត្រីបឹងកក់១៣រូបនោះវិញ។[6]

ជាលទ្ធផលនៃការចេញមុខរបស់ចុងចោទក្នុងការតវ៉ាទាមទារឲ្យមានការដោះលែងស្ត្រីទាំង១៣រូបនោះ ព្រមជាមួយការនិយាយមិនលាក់លៀមតាមរយៈបទសម្ភាសន៍នានាជាមួយសារព័ត៌មាននោះ អាជ្ញាធរបានចាប់ផ្តើមដៅមុខចុងចោទ ហើយចុងចោទធ្លាប់ត្រូវបានគេគំរាមកំហែង និងសម្លុតគំរាមជាពាក្យសំដីផងដែរ។[7] ចុងចោទបានមានប្រសាសន៍ថា

---

[6] ដោះលែងស្ត្រី១៥នាក់ «អ្នកការពារសិទ្ធិមនុស្ស អ្នកស្រី យោម បុប្ផា» (របាយការណ៍សង្ខេប) ចេញផ្សាយនៅខែធ្នូ ឆ្នាំ២០១២ http://www.licadho-cambodia.org/reports.php?perm=173

[7] ដូចខាងលើ។

ខ្លួនត្រូវបានប៉ូលីសប្រាប់ម្តងហើយម្តងទៀត ថារូបខ្លួនត្រូវបានគេដាក់ក្នុង«បញ្ជីខ្មៅ» ហើយនឹងអាចប្រឈមបញ្ហានាពេលឆាប់ៗនេះ។[8]

នៅវេលាព្រឹកថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ នៅពេលបានទទួលទូរស័ព្ទហៅពីមន្ត្រីប៉ូលីសមូលដ្ឋាន ដែលបានប្រាប់ថាពួកគាត់ត្រូវមកធ្វើអត្តសញ្ញាណប័ណ្ណឡើងវិញដើម្បីអាចបោះឆ្នោតបាននោះ ចុងចោទ និងលោក លួស សាខន បានចាកចេញពីផ្ទះសំដៅទៅទីនោះ។ នៅពេលពួកគាត់ចេញពីផ្ទះ ប្រហែលជាម៉ោង៨.២០នាទីព្រឹក ពួកគាត់ត្រូវបានមន្ត្រីប៉ូលីសក្នុងសំលៀកបំពាក់ស៊ីវិល ចាប់អូសចូលឡានតែម្តង។[9] ចុងចោទ បានរាយការណ៍ឲ្យដឹងថា រូបខ្លួនត្រូវបានគេបង្ខំឲ្យផ្តិតមេដៃលើឯកសារជាច្រើន ហើយបន្ទាប់មកត្រូវបានគេបញ្ជូនភ្លាមៗទៅកាន់ពន្ធនាគារព្រៃសរ ដោយខ្លួនមិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួន ឬការចោទប្រកាន់ណាមួយមកលើខ្លួននោះឡើយ។[10] ក្រោយមក ចុងចោទ និងលោក លួស សាខន ត្រូវបានគេចោទប្រកាន់ពីបទ «ហឹង្សាដោយចេតនាមានស្ថានទម្ងន់» ពាក់ព័ន្ធនឹងការវាយប្រហារដោយហឹង្សាលើជនរងគ្រោះដើមបណ្តឹងដែលត្រូវបានគេអះអាងឡើង ថាពួកគាត់ទាំងពីរបានរៀបផែនការវាយប្រហារនេះឡើង។

ចុងចោទត្រូវបានបញ្ជូនភ្លាមៗទៅកាន់ទីឃុំឃាំងបណ្តោះអាសន្នមុនសវនការ ខណៈដែលស្វាមីរបស់ចុងចោទត្រូវបានគេដោះលែងឲ្យនៅក្រៅឃុំ។ ចុងចោទ និងស្វាមីរបស់ចុងចោទ ត្រូវបានគេជំនុំជម្រះក្តីនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ស្របពេលសវនាការរបស់បងប្អូនប្រុសពីររូបរបស់ចុងចោទ គឺលោក យ៉ោម កន្លង់ និង លោក យ៉ោម សិទ្ធិ ដែលត្រូវបានគេចោទប្រកាន់ថា ជាអ្នកធ្វើសកម្មភាពតាមការបញ្ជារបស់ចុងចោទ ឲ្យធ្វើការវាយប្រហារលើជនរងគ្រោះ បើទោះបីជាបងប្អូនប្រុសទាំងពីរនាក់នោះ មិនបានរស់នៅក្នុងតំបន់នោះអស់ជាច្រើនឆ្នាំមកហើយក៏ដោយ។ បងប្អូនប្រុសទាំងពីរនាក់នោះមិនមានវត្តមាននៅក្នុងសវនាការនោះទេ ហើយអ្នកទាំងពីរត្រូវបានគេកាត់ទោសកំបាំងមុខ ឲ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ ហើយដីកាចាប់ខ្លួនអ្នកទាំងពីរត្រូវបានគេសម្រេចរួចហើយ។ ចុងចោទ និងមនុស្សបីនាក់នេះ ត្រូវបានបង្គាប់ឲ្យរួមគ្នាសងជម្ងឺចិត្តដល់ជនរងគ្រោះម្នាក់ៗ (ដើមបណ្តឹង) នូវទឹកប្រាក់ចំនួន៣០លានរៀល (៧៥០០ដុល្លារអាមេរិក)។[11]

បន្ទាប់ពីការចាប់ខ្លួនចុងចោទកាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២រួចមក បណ្តាសកម្មជនភូមិបឹងកក់ រួមជាមួយនឹងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកតស៊ូមតិខាងសិទ្ធិមនុស្សជាតិនិងអន្តរជាតិ បានរិះគន់យ៉ាងខ្លាំងចំពោះការចោទប្រកាន់មកលើនឹងចុងចោទ ហើយបានអំពាវនាវឲ្យមានការដោះលែងរូបចុងចោទវិញ។ សកម្មជនបឹងកក់បានធ្វើការតវ៉ាដោយសន្តិវិធីជាច្រើនដងប្រឆាំងនឹងការដាក់ចុងចោទក្នុងពន្ធនាគារ។ គួរឲ្យកត់សម្គាល់នោះគឺថា នៅថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៣ បាតុករមួយក្រុមមកពីសហគមន៍បឹងកក់ បានធ្វើបាតុកម្មសំដៅទៅក្រសួងយុត្តិធម៌ ទាមទារឲ្យដោះលែងចុងចោទ។ នៅពេលដែលគ្មានតំណាងក្រសួងធ្វើការឆ្លើយតប ក្រុមបាតុករបានបន្តធ្វើដំណើរទៅផ្ទះនាយករដ្ឋមន្ត្រី។ ក្រុមបាតុករត្រូវបានក្រុមប៉ូលីស និងប៉ូលីសយោធាប្រហែលជា២០០នាក់ និងក្រោយមកមានក្រុមសន្តិសុខនៅសួនច្បារជិតនោះ បានរួមទប់ស្កាត់។ អំពើហឹង្សាបានកើតឡើង នៅពេលដែលក្រុមសន្តិសុខបាត់បង់ម្ចាស់ការ ហើយបានចាប់ផ្តើមវាយប្រហារដោយកម្លាំងបាយលើក្រុមបាតុករ។ បាតុករចំនួន៦រូបត្រូវបានរងរបួសជាទម្ងន់។ ក្នុងចំណោមអ្នកទាំង៦នាក់នោះ គឺមានលោក លួស សាខន ដែលត្រូវបានក្រុមសន្តិសុខមានគ្នាប្រហែលជា១០នាក់បានព័ទ្ធវាយ ហើយជាលទ្ធផលគាត់ត្រូវបានគេវាយបំបាក់ធ្មេញជាច្រើន និងជើងរបស់គាត់ត្រូវបានវាយយ៉ាងដំណំ។ ក្នុងនោះក៏មាន អ្នកស្រីញ៉ុក សុផាត ដែលត្រូវបានគេវាយបំបាក់ដៃ ហើយកែងដៃរបស់អ្នកស្រីថ្លោះចេញពីគ្នា ព្រមជាមួយនឹងអ្នកស្រី ង៉ែត យុន ដែលជាស្ត្រីវ័យប្រហែលជា៧០ឆ្នាំ

---

[8] ក្រុមសង្គមស៊ីវិលជាច្រើន «បញ្ចប់នូវការចោទប្រកាន់ផ្នែកច្បាប់ ហើយដោះលែងអ្នកស្រី យោម បុប្ផា» (សេចក្តីថ្លែងការណ៍) ចេញផ្សាយនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ http://freethe15.wordpress.com/2012/12/27/joint-cso-statement-legal-persecution-of-land-rights-activists-must-end-yorm-bopha-should-be-released-immediately-and-unconditionally/

[9] ម.ស.ម.ក «សកម្មជនបឹងកក់ត្រូវបានចាប់ខ្លួន និងត្រូវបានសាលាតំបូងរាជធានីភ្នំពេញចោទប្រកាន់» (សេចក្តីប្រកាសព័ត៌មានបន្ទាន់) ចេញផ្សាយនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២
http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=26&id=5

[10] កិច្ចសម្ភាសន៍ជាមួយចុងចោទ នៅពន្ធនាគារ។

[11] សង្ខេបសាលក្រមនៃករណីនេះ

ត្រូវបានគេវាយសន្លប់បាត់ស្មារតី។[12]

ក្រុមរត់ម៉ូតូឌុបនៅទីក្រុងភ្នំពេញ ក៏បានធ្វើបាតុកម្មជាច្រើនដងលើករណីនេះផងដែរ ដែលជាទូទៅបាតុកម្មនោះធ្វើឡើងប្រឆាំងនឹងក្រុមអង្គការមិនមែនរដ្ឋាភិបាលដែលបានជួយជ្រោមជ្រែងដល់ចុងចោទ។ ក្រុមអ្នករត់ម៉ូតូឌុបដែលបានចូលរួមក្នុងបាតុកម្មនោះត្រូវបានគេអះអាងថាត្រូវបានគេជួលឲ្យចូលរួមធ្វើបាតុកម្មនេះ ប៉ុន្តែការអះអាងនេះត្រូវប្រានចោលដោយប្រធានសមាគមរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជា ឬគេហៅថាក្រុមអ្នករត់ម៉ូតូឌុប ដែលជាអ្នកគ្រាំទ្រដល់ដើមបណ្តឹងដែលអះអាងថាជាជនរងគ្រោះ។[13]

ចុងចោទបានដាក់បណ្តឹងឧទ្ធរណ៍ក្នុងខែមករា ឆ្នាំ២០១៣ ហើយបច្ចុប្បន្នកំពុងរងចាំការជំនុំជម្រះបណ្តឹងឧទ្ធរណ៍នេះ ដែលត្រូវបានកំណត់ធ្វើនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣។ បណ្តឹងឧទ្ធរណ៍លើកទីពីររបស់ចុងចោទ សូមនៅក្រៅឃុំដោយមានការធានា ត្រូវបានតុលាការកំពូលបដិសេធ កាលពីថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៣ ដោយឈរលើមូលដ្ឋានថាចុងចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព ហើយបើទោះបីជាចុងចោទបានថ្លែងថារូបខ្លួនមានបញ្ហាបេះដូងដែលទាមទារនូវការព្យាបាលជាប្រចាំក្តី ចុងចោទមិនមានភ័ស្តុតាងបញ្ជាក់ពីជម្ងឺនេះនោះទេ ។

### *ការវាយប្រហារដែលត្រូវបានគេអះអាងឡើង*

ការវាយប្រហារដែលត្រូវបានគេលើកឡើងនោះកើតឡើងនៅប្រមាណជាម៉ោង៧ល្ងាច នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ នៅពេលដែលជនរងគ្រោះ ត្រូវជាបងប្អូនជីដូនមួយជាមួយគ្នា គឺលោក ង៉ែត ចិត្ត និងលោក វ៉ាត់ ថៃសេង បានកំពុងផឹកស្រាសនៅក្នុងតៀមស្រាមួយ បិតក្នុងផ្ទះលេខ៥ ផ្លូវ៨៦ ភូមិ២ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ទីក្រុងភ្នំពេញ។ ជនរងគ្រោះដែលជាដើមបណ្តឹងបានអះអាងថាពួកគាត់ត្រូវបានមនុស្សពីរនាក់វាយប្រហារ ដែលក្នុងនោះម្នាក់កាន់ពូថៅ ហើយម្នាក់ទៀតកាន់ទូលីវែស។

ចុងចោទបានថ្លែងថា ខ្លួនបានចេញក្រៅដើម្បីហាត់ប្រាណ ហើយនៅពេលដែលខ្លួនធ្វើដំណើរសំដៅទៅផ្ទះវិញ ខ្លួនក៏បានឈប់ដើម្បីជជែកជាមួយប្តីរបស់ខ្លួន និងអ្នកជិតខាង គឺអ្នកស្រី ផាន់ ឈុនរ៉េត ដែលបិតនៅចម្ងាយប្រហែលជា១៥ម៉ែត្រពីទីកន្លែងកើតហេតុនៃការវាយប្រហារ។ នៅពេលនោះ ក៏មានជម្លោះមួយកើតឡើងនៅតៀមស្រានោះ ដែលចុងចោទនិងស្វាមី ក៏បានទៅមើលថាមានអ្វីកើតឡើង។ ពួកគាត់បានឈរនៅពីខាងក្រៅហាងស្រានោះ ប៉ុន្តែពួកគាត់មិនបានដើរចូលទៅខាងក្នុងនោះទេ។

បងប្អូនប្រុសរបស់ចុងចោទ គឺលោក យ៉ោម កន្លង់ និងលោក យ៉ោម សិទ្ធិ ត្រូវបានគេរាយការណ៍ថា បានប្រព្រឹត្តអំពើហឹង្សាមកលើជនរងគ្រោះ ដោយសារតែជនរងគ្រោះនោះត្រូវបានសង្ស័យថាបានលួចកញ្ចក់ឡានរបស់ចុងចោទ។ ជនរងគ្រោះម្នាក់បានអះអាងថា គាត់ធ្លាប់បានរស់នៅជិតផ្ទះរបស់បងប្អូនប្រុសពីរនាក់របស់ចុងចោទអស់រយៈពេល៣ឆ្នាំ ហើយមិនធ្លាប់មានទំនាស់ជាមួយគ្នានោះទេ។ កញ្ចក់ឡានរបស់ចុងចោទត្រូវបានគេលួចមួយខែមុនព្រឹត្តការណ៍វាយប្រហារកើតឡើង ហើយចុងចោទក៏បានដាក់បណ្តឹងទៅប៉ូលីសរួចហើយដែរ។ ចុងចោទបានអះអាងថា ខ្លួនមិនបានដឹងថាអ្នកណាជាអ្នកលួចនោះទេ ហើយខ្លួនក៏មិនដែលបានឃើញជនរងគ្រោះនោះពីមុនមកដែរ។ ពលរដ្ឋជាច្រើនដែលរស់នៅក្នុងតំបន់នោះ ក៏ត្រូវបានចោរលួចគាស់កញ្ចក់រថយន្តដំណាលគ្នានោះដែរ។

ជនរងគ្រោះម្នាក់ ឈ្មោះ វ៉ាត់ ថៃសេង ត្រូវបានគេចាក់ប្អូនដងនឹងទូលីវែស ហើយម្នាក់ទៀតគឺលោក ង៉ែត ចិត្ត បានរងរបួសក្បាលប៉ះពាល់ដល់ប្រសៃប្រសាទ រហូតដល់បាត់បង់ការចងចាំ ដោយសារត្រូវបានគេកាប់នឹងពូថៅ។[14]

---

[12] ម.ស.ម.ក «ភាពឃោរឃៅកាន់តែខ្លាំង ភាពអាម៉ាស់ក៏មានកាន់តែច្រើនសម្រាប់កម្ពុជា» (សេចក្តីថ្លែងការណ៍) ចេញផ្សាយនៅថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១៣
http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=369&id=5

[13] ម៉ី ទិត្យធារ៉ា និងសាន រ៉ៃល «ក្រុមអ្នករត់ម៉ូតូឌុបធ្វើបាតុកម្មនៅមុខម.ស.ម.ក» កាសែតឌឹភ្នំពេញប៉ុស្ត៍ ចេញផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣

[14] សាន រ៉ៃល និង ភ័ក្រ សេងលី «អ្នករត់ម៉ូតូឌុបបឹងកក់បានវិលត្រលប់ទៅធ្វើការវិញ» កាសែតឌឹភ្នំពេញប៉ុស្ត៍ ចេញផ្សាយថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២ http://www.phnompenhpost.com/2012100559128/National/boeung-kak-motodop-returns-to-work.html

## ៤. បទចោទ និងភស្តុតាង

សវនាការក្តីរបស់ចុងចោទ និងអ្នកទាំងបីនាក់ទៀត បានប្រព្រឹត្តទៅនៅសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ក្នុងរយៈពេលប្រហែលជា៥ម៉ោង។ សាក្សីចំនួន៤រូបបានមានវត្តមាន ដែលក្នុងនោះបីរូបជាសាក្សីដាក់បន្ទុក និងមួយរូបជាសាក្សីដោះបន្ទុក។ ចុងចោទ និងស្វាមីរបស់ចុងចោទ ដែលមានវត្តមានក្នុងពេលនោះ បានផ្តល់សក្ខីកម្មរបស់ខ្លួនមុនដំបូងគេបង្អស់ពាក់ព័ន្ធនឹងការវាយប្រហារ។ បន្ទាប់មក តុលាការបានសាកសួរដល់ជនរងគ្រោះដើមបណ្តឹង និងសាក្សីបួនរូប។ បទចោទប្រឆាំងនឹងចុងចោទ និងភស្តុតាងដាក់បង្ហាញដើម្បីគាំពារដល់បទចោទនោះ នឹងត្រូវបានលើកមកធ្វើការពិនិត្យពិច័យក្នុងផ្នែកបន្ទាប់នេះ។

ចុងចោទត្រូវបានចោទប្រកាន់ពីបទ «ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស» តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ មាត្រា ២១៨ «ស្ថានទម្ងន់ទោស» ចែងថា៖

*«អំពីហឹង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅដប់លានរៀល កាលបើអំពើហឹង្សានេះ បានប្រព្រឹត្ត៖*

*១. ដោយមានការគិតទុកជាមុន។*

*២. ដោយប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ។*

*៣. ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត។*

ហឹង្សាដោយចេតនាមិនត្រូវបានគេផ្តល់និយមន័យក្នុងក្រមព្រហ្មទណ្ឌនោះទេ អាស្រ័យហេតុនេះនិយមន័យហឹង្សាក្នុងវចនានុក្រមអ័បហ្សូបនឹងត្រូវយកមកប្រើប្រាស់ក្នុងបរិបទការវិភាគច្បាប់នេះ៖

*«អាកប្បកិរិយាដោយប្រើកម្លាំងបាយប៉ុនប៉ងធ្វើឲ្យនរណាម្នាក់ ឬអ្វីមួយមានការឈឺចាប់ ត្រូវបានបំផ្លាញ ឬបាត់បង់ជីវិត»*[15]

យោងតាមសេចក្តីបញ្ជាក់ និងសក្ខីកម្មរបស់ជនជាប់ចោទ និងជនរងគ្រោះដើមបណ្តឹង អំពើហឹង្សានោះបានកើតឡើងនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ នៅតៀមស្រាមួយនៅជិតផ្ទះរបស់ចុងចោទ ហើយអំពើហឹង្សានោះមានការប្រើកម្លាំងបាយប៉ុនប៉ងធ្វើឲ្យជនរងគ្រោះរងការឈឺចាប់។ ជនរងគ្រោះដើមបណ្តឹងបានរងរបួសដោយសារអំពើនេះ ហើយត្រូវបានបញ្ជូនទៅព្យាបាល។ ភស្តុតាងជារូបភាពនៃរបួស ព្រមជាមួយនឹងរបាយការណ៍របស់មន្ទីរពេទ្យ មានភ្ជាប់ក្នុងសំណុំរឿងក្តីនេះផងដែរ។ តាមរយៈ របាយការណ៍របស់មន្ទីរពេទ្យ និងការអះអាងនានាពីសាក្សីនិងភាគីក្នុងសំណុំរឿងក្តីនេះ សរឲ្យឃើញថារបួសនោះគឺពិតជាបណ្តាលមកពីការប៉ុនប៉ងដោយចេតនា តាមស្នាមរបួសដែលមើលឃើញ មិនមែនបណ្តាលមកពីគ្រោះថ្នាក់ដោយចៃដន្យនោះឡើយ។ យោងតាមសាក្សីដាក់បន្ទុក និងជនរងគ្រោះដើមបណ្តឹង អាវុធដែលត្រូវបានយកមកប្រើប្រាស់ក្នុងការវាយប្រហារនោះ គឺទូលីវីស និងពូថៅ ដែលនេះអះអាងបានថា របួសដែលកើតឡើងនោះ គឺកើតចេញពីចេតនាមិនមែនដោយសារគ្រោះចៃដន្យទេ។

ដោយសារថាអំពើហឹង្សាដោយចេតនានេះត្រូវបានសរឲ្យឃើញរួចហើយនោះ ដើម្បីកំណត់ថាអំពើមួយនេះមានស្ថានទម្ងន់ដែរឬយ៉ាងណា ចាំបាច់ត្រូវពិនិត្យព័ច័យថាតើទង្វើហឹង្សាដោយចេតនានេះ បានប្រព្រឹត្ត ១) *ដោយមានការគិតទុកជាមុន ២) ដោយប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ និង ៣) ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត។*

**៤.១** បើក្រឡេកមើលលើធាតុផ្សំទី១ គឺដោយមានការគិតទុកជាមុន ដែលមានចែងក្នុងមាត្រា ៧៨ នៃក្រមព្រហ្មទណ្ឌ ថា "ជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស"។ ជនល្មើស ត្រូវបានគេអះអាងថាមានកាន់អាវុធ ដែលនេះហាក់បង្ហាញឲ្យឃើញថាពួកគាត់បានសំដៅមកទីកើតហេតុដោយមានការត្រៀមទុក ហេតុដូចនេះទង្វើរបស់ពួកគាត់ពិតជាមានការគិតទុកជាមុនជាក់មែន។ ទោះជាយ៉ាងនេះក្តី អាវុធទាំងនោះគឺជាឧបករណ៍ដែលងាយរកបាន មាន

---

[15] វចនានុក្រមអ័បហ្សូបតាមប្រព័ន្ធអ៊ីនធឺណេត http://oxforddictionaries.com/definition/english/violence?q=violence

ដូចជាទូលីវីស និងពូថៅ ដែលពួកគាត់អាចរកបាននៅទីកើតហេតុនោះ ដោយមិនចាំបាច់គិតទុកជាមុននោះឡើយ។ ជាមួយគ្នានោះដែរ អង្គហេតុដែលថា ជនល្មើសដែលត្រូវបានគេចោទប្រកាន់ ពោលគឺបងប្អូនប្រុសរបស់អ្នកស្រី យ៉ោម បុប្ផា មិនមានវត្តមានក្នុងការសួរចម្លើយ រឹតតែធ្វើឲ្យមានផលលំបាក់ក្នុងការផ្សារភ្ជាប់ថាសកម្មភាពនោះត្រូវបានគិតទុកជាមុន ឬក៏ទង្វើនោះកើតឡើងនៅពេលនោះតែម្តង។

សម្រាប់ចុងចោទវិញ ព្រះរាជអាជ្ញាបានលើកឡើងថា ចុងចោទ និងស្វាមីគឺលោក លួស សាខន ជាអ្នករៀបចំផែនការអំពើវាយប្រហារនេះ ហើយបានបង្ហាញខ្លួននៅទីកើតហេតុ ដើម្បីមើលឃើញព្រឹត្តការណ៍នោះ។ យោងតាមជនរងគ្រោះដើមបណ្តឹង ចុងចោទបានប្រាប់ឲ្យបងប្អូនប្រុសរបស់ខ្លួនវាយប្រហារទៅលើពួកគាត់ ដោយបានលើកឡើងថាពួកគាត់បានលួចកញ្ចក់រថយន្តរបស់ចុងចោទ។

ទោះជាយ៉ាងនេះក្តី ជនរងគ្រោះដើមបណ្តឹងបានផឹកស្រាសជាច្រើនម៉ោងមុនព្រឹត្តិការណ៍បានកើតឡើង ហើយពួកគាត់បានសារភាពថា ពួកគាត់ស្រវឹង ហើយថាការចងចាំរបស់ពួកគាត់មានភាពស្រពិចស្រពិល។ បន្ថែមលើសនេះទៀត ភាពមិនស៊ីសង្វាក់គ្នារវាងសក្ខីកម្មទាំងនោះ ធ្វើឲ្យមានមន្ទិលសង្ស័យមិនគួរអាចជឿទុកចិត្តបាន។ ឧទាហរណ៍ លោក វ៉ាត់ ថៃសេង បានអះអាងថា លោក យ៉ោម កន្លង់ បានយកទូលីវីសចាក់រូបលោក ហើយលោក យ៉ោម សិទ្ធិបានប្រើពូថៅកាប់លើលោក ង៉ែត ចិត្ត។ តែលោក ង៉ែត ចិត្ត បានអះអាងថា យ៉ោម កន្លង់ជាអ្នកវាយប្រហារមកលើរូបខ្លួន មិនមែន លោក យ៉ោម សិទ្ធិនោះទេ។ បើទោះពីជាអង្គហេតុបង្ហាញថា ជនរងគ្រោះដើមបណ្តឹង បានផឹកស្រាជាច្រើនម៉ោងមុននេះ ហើយពេលព្រឹត្តិការណ៍វាយប្រហារកើតឡើងនោះ គឺយប់ងងឹតទៅហើយ ពួកគាត់ទាំងពីរបានអះអាងគួរឲ្យសង្ស័យអំពីទូលីវីសដែលត្រូវបានយកមកប្រើប្រាស់ជាអាវុធនោះ ដោយបានព្យាយាមអះអាងថាដងទូលីវីសនោះ គឺពណ៌ខៀវ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺថា ជនរងគ្រោះ ជាភាគីដើមបណ្តឹងក្នុងសំណុំរឿងក្តីនេះ ហើយពួកគាត់នឹងទទួលបានផលប្រយោជន៍ពីសំណងផ្លូវចិត្ត ក្នុងករណីដែលចុងចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព។ ក្រមនិតិវិធីព្រហ្មទណ្ឌបានចែងអំពីវិសមតិភាព ក្នុងមាត្រា ៣១២ ដែលថាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចមានឋានៈជាសាក្សីបានឡើយ។ ផ្ទុយទៅវិញ ក្នុងករណីរឿងក្តីនេះ សក្ខីកម្មពីជនរងគ្រោះត្រូវបានចាត់ទុកជាប្រភពភ័ស្តុតាងយ៉ាងសំខាន់ ក្នុងការកាត់ទោសចុងចោទ ស្វាមីរបស់ចុងចោទ និងបងប្អូនប្រុសរបស់ចុងចោទ។ ជនរងគ្រោះមានវត្តមានក្នុងសាលតុលាការតាំងពីដើមទីរហូតដល់ចប់ ដែលពួកគាត់អាចស្តាប់នូវរាល់សក្ខីកម្មរបស់បណ្តាសាក្សីផ្សេងទៀត ហើយពួកគាត់មិនត្រូវបានតម្រូវឲ្យធ្វើការស្បថស្បែនោះឡើយ។

សាក្សីដាក់បន្ទុកចំនួនបីរូប មិនបានអះអាងថា ខ្លួនបានឮចុងចោទធ្វើការណែនាំបងប្អូនប្រុសរបស់ខ្លួនឲ្យវាយប្រហារជនរងគ្រោះនោះទេ ហើយក្នុងករណីនេះ ភាពមិនស៊ីសង្វាក់រវាងសក្ខីកម្ម បានធ្វើឲ្យមានមន្ទិលសង្ស័យមិនអាចទុកចិត្តបានទៅលើសក្ខីកម្មទាំងនេះ។ សាក្សីទីមួយ គឺ លោក វ៉ាត់ សារ៉ាត់ បាននិយាយថា ចុងចោទបានចោទប្រកាន់ជនរងគ្រោះថាបានលួចកញ្ចក់រថយន្តរបស់ចុងចោទ ហើយថាចុងចោទ បានជួយដោះលែងប្អូនប្រុសរបស់ខ្លួន គឺលោក យ៉ោម កន្លង់ ក្នុងខណៈដែល លោក វ៉ាត់ សារ៉ាត់ចាប់ខ្លួនបាន។ ទោះជាយ៉ាងនេះក្តី សក្ខីកម្មរបស់លោក វ៉ាត់ ថៃសេង និងសាក្សីទីពីរ គឺ លោក អៃ ស៊ានហឿន គឺ មិនស៊ីសង្វាក់នឹងអំណះអំណាងរបស់លោក វ៉ាត់ សារ៉ាត់ ដែលថាគាត់ចាប់បានលោក យ៉ោម កន្លង់ នោះទេ។ លោក វ៉ាត់ ថៃសេង បានអះអាងថា លោក អៃ ស៊ានហឿនចាប់លោក យ៉ោម កន្លង់បាន ហើយ លោក អៃ ស៊ានហឿននេះ បើទោះបីជាបានអះអាងថាចាប់បប្អូនប្រុសម្នាក់របស់ចុងចោទបាននោះ លោកបានអះអាងថា គឺចាប់បានលោក យ៉ោម សិទ្ធិទៅវិញ។ អ្វីដែលត្រូវកត់សម្គាល់នោះគឺថា លោក វ៉ាត់ សារ៉ាត់ គឺជាឪពុករបស់លោក វ៉ាត់ ថៃសេង និងត្រូវជាឪពុកមារបស់លោក ង៉ែត ចិត្ត។ សាក្សីដាក់បន្ទុកទីបី គឺ អ្នកស្រី អានស៊ីវម៉ី បាននិយាយថា អ្នករត់ម៉ូតូឌុប គឺលោក អៃ ស៊ានហឿន ចាប់បានជនល្មើស មុនពេលដែលលោក វ៉ាត់ សារ៉ាត់បានមកដល់ទីតាំងកើតហេតុ។ នេះគឺផ្ទុយពីសក្ខីកម្មរបស់លោក អៃ ស៊ានហឿនដែលបានបញ្ជាក់ថា រូបលោករត់តាមក្រោយលោក វ៉ាត់ សារ៉ាត់ ឆ្ពោះទៅកាន់ទីតាំងកើតហេតុនោះ។

ថ្វីបើខ្វះភស្តុតាងជាក់លាក់ និងគួរឲ្យទុកចិត្តបានយ៉ាងណាក្តី តំណាងអយ្យការបានសំអាងថា ដោយយល់ឃើញថា ចុងចោទត្រូវបានគេលួចគាស់កញ្ចក់រថយន្ត ហើយថាជនល្មើសជាប់ពាក់ព័ន្ធនឹងចុងចោទ និងថាចុងចោទបានមានវត្តមាននៅទីកើតហេតុ ដូចនេះចុងចោទត្រូវតែជាអ្នកបានរៀបផែនការវាយប្រហារនោះ។ ផ្ទុយទៅវិញ ចុងចោទបាន

ផ្តល់សក្ខីកម្មថា កាលវេលាល្ងាចថ្ងៃទី៧ ខែសីហា នៅពេលដែលខ្លួនបានវិលត្រឡប់មកពីហាត់ប្រាណ ក៏បានជួបប្តី និង អ្នកជិតខាងគឺ អ្នកស្រី ផាន់ ឈុនរ៉េត ខ្លួនក៏បានឈប់ដើម្បីជជែកលេងទៅ។ នៅពេលនោះក៏បានឮជម្លោះកើតឡើង ចុងចោទ និងស្វាមី ក៏បានដើរសំដៅទៅមើលព្រឹត្តការណ៍នោះទៅ។ ពួកគាត់បានឈរមើលពីខាងក្រៅតៀមស្រានោះ។ អង្គហេតុដែលថា ចុងចោទមានវត្តមាននៅទីកើតហេតុ ហើយថាចុងចោទជាប់សាច់ញាតិនឹងជនល្មើស នោះមិនមានន័យថា ចុងចោទបានផ្តើមឲ្យមានជម្លោះនោះកើតឡើងនោះទេ។ ជាងនេះទៀតនោះ ចុងចោទបានអះអាងថា ខ្លួនមិនស្គាល់ជន រងគ្រោះទាំងពីរនោះទេ ហើយថាបើទោះបីជាកញ្ចក់ថេយន្តរបស់ខ្លួនត្រូវបានគេលួចគាស់ ដែលនេះបានកើតឡើងចំពោះ សមាជិកសហគមន៍ដទៃទៀតដែរនោះ ខ្លួនមិនដឹងថាអ្នកណាជាអ្នកលួចនោះឡើយ។

ដោយយល់ឃើញនូវការដាក់បន្ទុកទៅលើសក្ខីកម្មដែលមិនស៊ីសង្វាក់គ្នា ជាពិសេសប្រភពសំខាន់ពីជនរងគ្រោះ ដែលមិនបានធ្វើការស្បថស្បែថានឹងនិយាយតែការពិតអំពីឧបទ្ទវហេតុនោះ នេះបង្ហាញថាមិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការ បញ្ជាក់ថា ចុងចោទបានគ្រោងទុកជាមុនក្នុងការវាយប្រហារនោះទេ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថាវិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

៤.២ ធាតុផ្សំទីពីរនោះ គឺពាក់ព័ន្ធនឹងការប្រើអាវុធឬគំរាមកំហែងនឹងអាវុធក្នុងការធ្វើសកម្មភាពហឹង្សាដោយ ចេតនា។ ក្នុងនេះ យើងនឹងមិនធ្វើការវិភាគទៅលើធាតុផ្សំនៃការគំរាមកំហែងនឹងអាវុធនោះទេ ដោយយល់ឃើញនូវភស្តុតាង ដែលបានកសាងឡើងគឺអាវុធពិតជាត្រូវបានប្រើប្រាស់មែន។ យោងតាមសក្ខីកម្មរបស់សាក្សីដាក់បន្ទុក និងការអះអាង របស់ជនរងគ្រោះដើមបណ្តឹង អាវុធពីរដែលលោក យ៉ោម កន្លង់ និងលោក យ៉ោម សិទ្ធិ បានប្រើប្រាស់ គឺទូលីវែ និងពូថៅ។ តែទោះជាយ៉ាងណាក៏ដោយ ដូចបានរៀបរាប់ខាងលើ ភាពមិនស៊ីសង្វាក់គ្នារវាងសក្ខីកម្មរបស់សាក្សីនិងជនរងគ្រោះ ដើមបណ្តឹង ធ្វើឲ្យពិបាកទុកចិត្តបានចំពោះភស្តុតាងទាំងនេះ។ អាស្រ័យហេតុនេះហើយ ពិតជាលំបាកជឿលើសក្ខីកម្ម ដែល ជាភស្តុតាងពាក់ព័ន្ធនឹងការប្រើអាវុធនេះណាស់។ លើសនេះទៀតនោះ ភស្តុតាងជាក់ស្តែង ដូចជាអាវុធដែលបានប្រើប្រាស់ មិនត្រូវបានគេប្រមូលទុកពីទីកន្លែងកើតហេតុនោះឡើយ ដោយសារថាប៉ូលីស ឬតុលាការមិនបានធ្វើការស៊ើបអង្កេតភ្លាមៗ ពាក់ព័ន្ធនឹងការវាយប្រហារនោះទេ។ ការណ៍នេះធ្វើឲ្យលំបាកក្នុងការបញ្ជាក់បានថា អាវុធជាក់លាក់ទាំងនោះពិតជាត្រូវបាន ជនល្មើស គឺលោក យ៉ោម កន្លង់ និងលោក យ៉ោម សិទ្ធិ ប្រើប្រាស់ដែរឬយ៉ាងណា តែយ៉ាងណាក្តី ពិនិត្យតាមសណ្ឋាននៃ របួសរបស់ជនរងគ្រោះដើមបណ្តឹងនោះ ទំនងថាអាវុធបែបនោះត្រូវបានប្រើប្រាស់ពិតមែន។ សម្រាប់ចុងចោទវិញ ក្នុងករណីដែលអាវុធទាំងនោះពិតជាត្រូវបានគេប្រើប្រាស់ ឬគំរាមកំហែងនឹងអាវុធមែននោះ ដើម្បីកំណត់ថាធាតុផ្សំនេះអាច អនុវត្តចំពោះចុងចោទបាន ចាំបាច់តុលាការត្រូវបង្ហាញថា ចុងចោទជាអ្នកផ្តួចផ្តើមគំនិត ឬអ្នកសមគំនិតឲ្យប្រព្រឹត្តអំពើ ឧក្រិដ្ឋកម្មនោះដូចមានចែងក្នុងធាតុផ្សំទីបី។

៤.៣(ក) រាល់សាក្សី ជនរងគ្រោះដើមបណ្តឹង និងចុងចោទបានទទួលស្គាល់ថា ចុងចោទមិនមែនជាជនល្មើស ប្រព្រឹត្តអំពើហឹង្សានោះដោយផ្ទាល់នោះទេ។ ទោះជាយ៉ាងណាក្តី ធាតុផ្សំទីបីនៃបទចោទបានបញ្ជាក់ថា ចុងចោទអាចជាអ្នក ផ្តើមគំនិត និងជាអ្នកសមគំនិតប្រព្រឹត្តអំពើហឹង្សាដោយចេតនា ហើយជាលទ្ធផលត្រូវទទួលទោសពិន័យដូចចារី ឬសហចារី ដែរ។

អ្នកផ្តើមគំនិត ត្រូវបានផ្តល់និយមន័យតាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ដូចតទៅ៖

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល៖

១. ជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា

២. បង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការល្បួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

មាត្រា ២៨ បន្តចែងថា អ្នកផ្តើមគំនិតនឹងត្រូវអាចផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបាន សម្រេច ឬបានប៉ុនប៉ង ហើយថាអ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម «*ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ*»។

យោងតាមជនរងគ្រោះដើមបណ្តឹង ចុងចោទបានណែនាំបងប្អូនប្រុសរបស់ខ្លួនឲ្យវាយប្រហារពួកគេ ដោយបាន

ចោទប្រកាន់ថាពួកខ្លួនបានលួចកញ្ចក់ចៃយន្តរបស់ចុងចោទ។ គ្មានសាក្សីណាមួយក្នុងចំណោមសាក្សីទាំងបួននាក់នោះបានផ្តល់សក្ខីកម្មថាបានឮចុងចោទណែនាំឲ្យបងប្អូនប្រុសរបស់ខ្លួនវាយប្រហារលើជនរងគ្រោះដើមបណ្តឹងនោះឡើយ។ អ្នកស្រី ផាន់ ឈុនរ៉េត ដែលជាអ្នកជិតខាងរបស់អ្នកស្រី យ៉ោម បុប្ផា និងលោក លួស សាខន បាននិយាយថា បន្ទាប់ពីជម្លោះទាស់ទែងត្រូវបានបញ្ចប់ មានបុរសមិនស្គាល់អត្តសញ្ញាណមួយរូបបានដើរសំដៅមកផ្ទះគាត់ ដែលចុងចោទ និងស្វាមីរបស់ចុងចោទបាននៅទីនោះដែរនៅពេលនោះ ហើយបានអះអាងថាចុងចោទជាអ្នកទទួលខុសត្រូវក្នុងរឿងវាយប្រហារនោះ។ នៅពេលដែលគាត់សួរទៅបុរសនោះ ថាហេតុអ្វីបានជាគាត់និយាយបែបនោះ គាត់មិនឆ្លើយទេ។

ថ្វីបើសាក្សីគឺលោក វ៉ាត់ សារ៉ាត់ បានផ្តល់សក្ខីកម្មថា គាត់បាននាំជនរងគ្រោះទៅដាក់បណ្តឹងដល់ប៉ូលីសមូលដ្ឋាននាយប់ដែលពួកគាត់ទទួលរងរបួសក្តី លុះច្រើនសប្តាហ៍ក្រោយមក ទើបចុងចោទ និងលោក លួស សាខន ត្រូវបានប៉ូលីសឃាត់ខ្លួន និងត្រូវបានគេចោទប្រកាន់ជាផ្លូវការ។ ត្រង់ចំណុចនេះគឺជាបញ្ហា ដោយសារថាមានចន្លោះពេលវេលាមួយសម្រាប់ឲ្យជនរងគ្រោះដើមបណ្តឹង និងសាក្សីដាក់បន្ទុកអាចធ្វើការឃុបឃិតគ្នាបាន។ ជាការចាំបាច់ណាស់ ដែលការស៊ើបអង្កេតមិនគួរត្រូវបានពន្យាពេលយូរឡើយ ដែលអាចធ្វើឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ជនល្មើសឃុបឃិតគ្នា ហើយធ្វើឲ្យការស៊ើបអង្កេតនោះបញ្ចប់ដោយខាតប្រយោជន៍ដល់ភាគីខាងដាក់បន្ទុក និងភាគីដោះបន្ទុក។ ដូចបានលើកខាងដើម ដោយសារតែការស៊ើបអង្កេតមានការយឺតយ៉ាវ ភស្តុតាងជាក់ស្តែងមិនត្រូវបានគេប្រមូលទុកពីទីកន្លែងកើតហេតុនោះទេ ដែលនេះបង្កជាផលលំបាកសម្រាប់តំណាងអយ្យការក្នុងការផ្សារភ្ជាប់ករណីរឿងក្តី។

សក្ខីកម្មរបស់ជនរងគ្រោះដើមបណ្តឹង គឺជាភស្តុតាងតែមួយមុខគត់ក្នុងការគាំទ្រដល់បទចោទដែលថា ចុងចោទបានណែនាំផ្ទាល់ដល់បងប្អូនប្រុសរបស់ចុងចោទឲ្យវាយប្រហារមកលើខ្លួន។ ជនរងគ្រោះដើមបណ្តឹងមានសភាពស្រវឹងនៅពេលដែលកើតព្រឹត្តិការណ៍វាយប្រហារនោះ ដោយបានផឹកស៊ីកាលពីវេលាម៉ោងប្រហែល៤រសៀល ហើយអំណះអំណាងនានារបស់ជនរងគ្រោះគឺ មិនស៊ីសង្វាក់គ្នានោះទេ ដូចបានឃើញខាងដើម។

ភស្តុតាងដែលបានដាក់បង្ហាញនូវតុលាការ បន្សល់នូវវិសាលភាពដែលគួរឲ្យសង្ស័យជាច្រើនចំពោះការដែលលើកថា ចុងចោទបានផ្តើមគំនិតឲ្យប្រព្រឹត្តអំពើហឹង្សានោះឡើង។

៤.៣(ខ) តួនាទីដែលនៅសល់ ដែលអាចបង្ហាញថាចុងចោទមានទំនាក់ទំនងក្នុងអំពើវាយប្រហារនេះ គឺអ្នកសមគំនិត។ មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ចែងអំពីនិយមន័យនៃអ្នកសមគំនិម ដូចតទៅ៖

*«ត្រូវចាត់ទុកជាអ្នកសមគំនិតក ចំពោះបុគ្គលណាដែលជួយសម្រួល ដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។»*

មាត្រា ២៩ បានបញ្ជាក់ថា អ្នកសមគំនិតអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬ បានប៉ុនប៉ង។ មាត្រានេះក៏បានចែងថា អ្នកសមគំនិតនៃបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នា នឹងចារីដែរ។

យោងតាមការអះអាងរបស់សាក្សីដាក់បន្ទុក និងជនរងគ្រោះដើមបណ្តឹងនោះ ចុងចោទបានជួយដោះលែងប្អូនប្រុសរបស់ខ្លួន នៅពេលដែលរូបលោកត្រូវបានសាក្សីម្នាក់ក្នុងចំណោមសាក្សីដែលនៅទីកើតហេតុនោះចាប់ខ្លួនបាន។ ចុងចោទបដិសេធថាបានជួយដោះលែងប្អូនប្រុសខ្លួន ហើយបាននិយាយថា រូបខ្លួនមិនបានទាំងចូលទៅខាងក្នុងផ្ទះដែលកើតហេតុនោះផង។ បន្ថែមលើសនោះ ការជួយដោះលែងនរណាម្នាក់ បន្ទាប់ពីព្រឹត្តិការណ៍វាយប្រហារកើតឡើងរួចហើយ មិនគួរជាហេតុផលដែលត្រូវពិចារណាថាជាការជួយផ្តល់ជំនួយ ឬការឧបត្ថម្ភដល់ការវាយប្រហារនោះឡើយ ដោយសំអាងថារឿងរ៉ាវបានកើតឡើងរួចទៅហើយ។

ដោយយោងលើអង្គហេតុថា មានតែភស្តុតាងតែមួយគត់ក្នុងការបង្ហាញថា ចុងចោទបានផ្តល់ជំនួយដល់ជនល្មើសម្នាក់ក្នុងចំណោមពីរនាក់នោះ គឺផ្អែកទាំងស្រុងលើសក្ខីកម្មរបស់ជនរងគ្រោះដើមបណ្តឹង និងសាក្សីដាក់បន្ទុក ដែលសក្ខីកម្មរបស់ពួកគេដូចបានបង្ហាញខាងដើម គឺមិនអាចជឿជាក់បាន ហើយភស្តុតាងមិនបានបង្ហាញឲ្យហួសពីការសង្ស័យដែលថាចុងចោទជាអ្នកសមគំនិតនៃបទមជ្ឈិមឡើយ។ បន្ថែមលើសនេះ រាល់ការអះអាងប្រឆាំងនឹងចុងចោទ គឺផ្អែកលើការសន្មត់ទុកជាមុនថាបងប្អូនប្រុសរបស់ចុងចោទគឺជាចារីផ្ទាល់។ បើទោះបីជាការវិភាគលើករណីក្តីរបស់បុរសទាំងពីរ គឺហួសពីវិសាលភាព

នៃការវិភាគច្បាប់នេះក៏ដោយ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺថា មិនមានភស្តុតាងជាក់លាក់ត្រូវបានកសាងឡើងដើម្បីកាត់ទោសបុរសទាំងពីរឡើយ ហើយអង្គហេតុដែលថាពួកគាត់មិនមានវត្តមាននៅតុលាការដើម្បីការពារក្តីទៀតសោតនោះ រឹតតែធ្វើឲ្យមានមន្ទិលលើការកាត់ទោសប្រឆាំងនឹងចុងចោទផងដែរ។ បទចោទប្រកាន់ត្រូវបានបំបែកជាផ្នែកៗ និងត្រូវបានវិភាគដូចរៀបរាប់ខាងលើ ក្នុងករណីប្រសិនបើ លោក យ៉ោម សិទ្ធិ និង យ៉ោម កន្លង់ ពិតជាបានប្រព្រឹត្តបទល្មើសបង្កអំពើហិង្សាដោយចេតនាមែន។ ប៉ុន្តែនេះមិនបានន័យថា ម.ស.ម.ក ជឿជាក់ថា លោក យ៉ោម សិទ្ធិ ឬ លោក យ៉ោម កន្លង់ បានពាក់ព័ន្ធក្នុងករណីវាយប្រហារនេះមែនទែននោះទេ។ ជាការពិត មិនមានភស្តុតាងគួរឲ្យទុកចិត្តបានត្រូវបានលើកមកបង្ហាញ ថាពួកគេបានមានវត្តមាននៅទីកន្លែងកើតហេតុ នៅពេលកើតព្រឹត្តការណ៍វាយប្រហារនោះទេ។ លើសនេះទៀត ចុងចោទ មិនបានទាំងស្គាល់ជនរងគ្រោះដើមបណ្តឹងឬសាក្សីដាក់បន្ទុកផងទេ បើទោះបីជាចុងចោទ ជាជនសកម្មម្នាក់ក្នុងសហគមន៍នោះ ហើយបានស្គាល់មនុស្សជាច្រើនក៏ដោយ តាមរយៈការប្រមូលហត្ថលេខាលើញត្តិ ឬការតវ៉ាប្រឆាំងនឹងការបំពានលើសិទ្ធិដីធ្លីជាដើម។

ជារួម ដូចបានបញ្ជាក់ខាងដើម ចុងចោទមិនមែនជាចារីផ្ទាល់ ហើយក៏មិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថា ចុងចោទអាចជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនោះដែរ ហេតុដូចនេះ មិនអាចអះអាងតាមផ្លូវច្បាប់បានថាចុងចោទបានប្រព្រឹត្តបទល្មើសហិង្សាដោយចេតនា មានស្ថានទម្ងន់ទោសនោះទេ។

## ៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺត្រូវបានធានាក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់ជាតិតាមរយៈការធ្វើសច្ចាប័នរបស់ប្រទេសកម្ពុជាកាលពីឆ្នាំ១៩៩២ (សូមមើលក្នុងផ្នែកសិទ្ធិជាមូលដ្ឋានខាងលើ)។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញបានចែងថា៖

«ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ»

មាត្រា ១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា៖

*«ជនគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំឲ្យតុលាការឯករាជ្យ និងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ និងកាតព្វកិច្ច និងលើភាពសមហេតុផល នៃការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌមកលើខ្លួន»*។

មាត្រា ១៤(១) នៃក.អ.ស.ព.ន ចែងថា៖

«ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី ។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជំរះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេច លើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី។»

ដូចការរៀបរាប់ខាងលើ នេះបង្ហាញឲ្យឃើញច្បាស់ថា ប្រព័ន្ធតុលាការមួយដែលឯករាជ្យ និងមិនលំអៀង គឺចាំបាច់ណាស់ដើម្បីធានាឲ្យបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ផ្ទុយទៅវិញ ក្នុងករណីរឿងក្តីនេះ អង្គហេតុដែលថាចុងចោទជាសកម្មជនមួយដែលលេចធ្លោ ហើយត្រូវបានគេគំរាមជាច្រើនដងមុនឈានដល់ការចាប់ខ្លួន កង្វះភស្តុតាងជាក់លាក់ក្នុងការដាក់បន្ទុកដល់ការកាត់ទោស និងករណីរឿងក្តីដទៃទៀតប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស[16]កន្លងមក ធ្វើឲ្យ

---

[16] ម.ស.ម.ក «ការវិភាគផ្នែកច្បាប់ស្តីពីការចោទប្រកាន់និងកាត់ទោសតំណាងសហគមន៍បឹងកក់១៣រូប កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២» (ការវិភាគផ្នែកច្បាប់) ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ តាមរយៈ http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=22&id=5 ; CCHR,

យើងជឿជាក់ថា តួអង្គនិតិប្រតិបត្តិបានដើរតួយ៉ាងសំខាន់នៅគ្រប់និតិវិធី និងការជ្រៀតជ្រែតដល់កិច្ចការតុលាការ បានជះឥទ្ធិពលដល់លទ្ធផលសវនាការផងដែរ។ មុនឈានដល់ការចាប់ខ្លួន ចុងចោទត្រូវបានគេគំរាម យាយី និងសម្លុតកំហែង[17]ជាច្រើនដង ហើយក្នុងអំឡុងពេលធ្វើយុទ្ធនាការទាមទារការដោះលែងសហគមន៍បឹងកក់ទាំង១៣រូបវិញ ប៉ូលីសក៏ត្រូវបានគេមើលឃើញថាបានដៅមុខសញ្ញាលើរូបចុងចោទ ផងដែរ។[18] គួរឲ្យកត់សម្គាល់ដែលនោះគឺថា កាលពីថ្ងៃទី១៩ ខែមិនា ឆ្នាំ ២០១៣ ប៉ុន្មានថ្ងៃមុនកាលបរិច្ឆេទសវនាការលើសំណើរលើកទីពីររបស់ចុងចោទសុំនៅក្រៅឃុំ នាយករដ្ឋមន្ត្រី លោក ហ៊ុន សែន បានយោងដល់ករណីក្តីរបស់ចុងចោទថា «ជាករណីសមញ្ញដែលអ្នកស្រីបានវាយគេ»[19] ហើយបានច្រានចោលទំនាក់ទំនងរវាងការឃុំខ្លួនអ្នកស្រី និងសកម្មភាពសាធារណៈរបស់អ្នកស្រីជាការងារការពារសិទ្ធិមនុស្ស។ ការធ្វើសេចក្តីអធិប្បាយជាសាធារណៈលើកិច្ចការតុលាការ ពីសំណាក់អ្នកដឹកនាំក្នុងជួររដ្ឋាភិបាល នៅពេលដែលករណីរឿងក្តីមិនទាន់បានបញ្ចប់ ហើយចុងចោទកំពុងរងចាំកាលបរិច្ឆេទសវនាការឧទ្ធរណ៍នោះ បានប៉ះពាល់ដល់ភាពយុត្តិធម៌នៃដំណើរការក្តី ហើយក៏ធ្វើឲ្យមានការព្រួយបារម្ភចំពោះឯករាជ្យភាពរបស់តុលាការ និងសិទ្ធិរបស់ចុងចោទទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ ជាពិសេសគឺការសន្មត់ជាមុនថាគ្មានទោស។ សេចក្តីអធិប្បាយជាច្រើន ដូចជាការលើកឡើងរបស់ព្រះរាជអាជ្ញា សេង ប៊ុនយាង ក្នុងអំឡុងពេលសវនាការបណ្តឹងឧទ្ធរណ៍លើកទីពីររបស់ចុងចោទសុំនៅក្រៅឃុំ ដែលបានយោងដល់ចុងចោទថា «ជាករណីពិសេស»[20] ក៏ចង្អុលឲ្យឃើញនូវចរិតលក្ខណៈនយោបាយក្នុងសំណុំរឿងក្តីនេះ ហើយនេះចោទជាសំណួរជុំវិញភាពស្មើគ្នាសម្រាប់ចុងចោទ នៅចំពោះមុខតុលាការដូចដែលបានចែងក្នុងមាត្រា ១៤ (១) នៃក.អ.ស.ព.ន ផងដែរ។

មាត្រា ១៤ ក៏បានបញ្ជាក់នូវធាតុផ្សំជាច្រើនថែមទៀត ជុំវិញការការពិនិត្យពិច័យឲ្យបានជិតដល់ជុំវិញស្ថានការណ៍ និងអង្គហេតុ ដែលនេះមិនត្រូវបានគេធានាក្នុងករណីរឿងក្តីរបស់ចុងចោទឡើយ។ ជាមូលដ្ឋាន ដើម្បីឲ្យការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌ នោះសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវតែបានគេគោរព។ ដូចនឹងរៀបរាប់ខាងក្រោម យ៉ាងហោចណាស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាក់លាក់មួយត្រូវបានគេបំពាន (ដែលនេះបន្ថែមនូវមន្ទិលដល់ភាពមិនលំអៀងរបស់តុលាការ) ដែលនេះមានន័យថា ចុងចោទមិនត្រូវបានទទួលបានពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ។

មាត្រា ១៤(២) នៃក.អ.ស.ព.ន ចែងថា៖

*«ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាមុនថា ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់»*។

ដូចបានរៀបរាប់ក្នុងផ្នែកទី៤ ពិតជាពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ចុងចោទនោះទេ។ លើសពីនេះ អង្គហេតុដែលថាចុងចោទត្រូវបានឃាត់ និងឃុំខ្លួនបណ្តោះអាសន្ន បើទោះបីជាមិនមានអំណះអំណាងគ្រប់គ្រាន់ (នឹងមានការរៀបរាប់ខាងក្រោម) និងអង្គហេតុដែលចុងចោទត្រូវបានកាត់ក្តីជំនុំជម្រះក្នុងឯកសណ្ឋានជាអ្នកទោស នេះសរឲ្យឃើញច្បាស់ថាចុងចោទត្រូវបានគេបដិសេធសិទ្ធិក្នុងការសន្មត់ជាមុនថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ចុងចោទត្រូវបានកំណត់។ ខណៈពេលដែលចុងចោទ ឋិតក្រោមការឃុំឃាំងបណ្តោះអាសន្ននោះ ស្ថានភាពរបស់ចុងចោទជាជនដែលមិនទាន់ត្រូវបានគេកាត់ទោស គឺមិនត្រូវបានគេផ្តល់ជូនឡើយ ដោយសារថាអាជ្ញាធរខកខានមិនបានធានាដល់សិទ្ធិរបស់ចុងចោទឲ្យនៅផ្សេងអំពីជនដែលត្រូវបានគេកាត់ទោសរួច ហើយគួរទទួលបានការប្រណិប័តន៍ដោយឡែកពីអ្នកទាំងនោះ ដូចមានចែងក្នុងមាត្រា ១០(២)(ក) នៃ ក.អ.ស.ព.នជាដើម។ ជាការពិត ចាប់តាំងអំពីការចាប់ខ្លួន ចុងចោទត្រូវបានគេចាត់ចែងឲ្យ

---

[17] សំដីរបស់អ្នកស្រី យ៉ោម បុប្ផា នៅពន្ធនាគារ។

[18] ដោះលែងសកម្មជនបឹងកក់១៥រូប «អ្នកស្រី យ៉ោម បុប្ផា» http://freethe15.wordpress.com/meet-bopha/

[19] អង្គការឃ្លាំមើលសិទ្ធិមនុស្ស «កម្ពុជា៖ តុលាការកំពូលរក្សាជំហរឲ្យសកម្មជននៅជាប់ពន្ធនាគារ» ចេញផ្សាយថ្ងៃទី២៩ ខែមិនា ឆ្នាំ ២០១៣ http://www.hrw.org/news/2013/03/29/cambodia-supreme-court-keeps-activist-jailed

[20] «សកម្មជន អ្នកស្រី យ៉ោម បុប្ផា ត្រូវបានតុលាការច្រានចោលសំណើរសុំនៅក្រៅឃុំ» កាសែតឌឹភ្នំពេញប៉ុស្តិ៍ ចេញផ្សាយនៅថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៣ http://www.phnompenhpost.com/2013032864750/National/activist-yorm-bopha-denied-bail.html

នៅក្នុងទីតាំងដូចអ្នកជាប់ពន្ធនាគារដែលបានកាត់ទោសរួចហើយ។ គួរឲ្យកត់សម្គាល់ផងដែរនោះគឺថា មានភាពមិនប្រក្រតីក្នុងនិតិវិធីតុលាការដទៃទៀតត្រូវបានគេអង្កេតឃើញផងដែរ ដូចជាការដែលចៅក្រមខកខានក្នុងការជម្រាបព័ត៌មាន និងពន្យល់អំពីសិទ្ធិរបស់ចុងចោទ ក្នុងការឆ្លើយតប ឬអាចនៅស្ងៀមមិនឆ្លើយបាន។

អ្វីដែលសំខាន់គួរឲ្យវិភាគនោះទៀតនោះគឺ អង្គហេតុដែលពាក់ព័ន្ធទាំងមុនសវនាការ និងអំឡុងពេលសវនាការដោយផ្សារភ្ជាប់នឹងធាតុផ្សំជាច្រើននៃមាត្រា ១៤(៣)នៃក.អ.ស.ព.ន ដែលចែងថា ៖ ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖

(ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។

មាត្រា ៩ (២) នៃក.អ.ស.ព.នចែងថា «ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឲ្យគេប្រាប់ឲ្យដឹងនៅពេលចាប់ខ្លួន និងត្រូវប្រាប់ឲ្យដឹងភ្លាមអំពីការចោទប្រកាន់» ដើម្បីអនុញ្ញាតឲ្យជនដែលត្រូវបានចាប់ខ្លួននោះអាច «ធ្វើការស្នើសុំនូវសេចក្តីសម្រេចទាន់ពេលវេលាពីភាពស្របច្បាប់នៃការឃុំខ្លួនមកលើខ្លួន ពីសំណាក់អាជ្ញាធរតុលាការដែលមានសមត្ថកិច្ច» (នេះយោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស)។[21]

បន្ថែមលើសនេះ មាត្រា ៤៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចែងថាអយ្យការគួរផ្តល់ព័ត៌មានទាន់ពេលវេលាដល់ជនជាប់ចោទ និងប្រភេទនៃបទល្មើសដែលត្រូវបានចោទប្រកាន់ប្រឆាំងមកលើខ្លួនជនជាប់ចោទ។ នៅពេលដែលចុងចោទត្រូវបានគេចាប់ខ្លួន ចុងចោទត្រូវបានមន្ត្រីប៉ូលីសក្នុងសំលៀកបំពាក់ស៊ីវិល ប្រានចូលក្នុងរថយន្តមិនមានស្លាកលេខមួយ ហើយត្រូវបានគេប្រាប់ឲ្យផ្តិតស្នាមមេដៃលើឯកសារជាច្រើន ដោយមិនត្រូវបានគេប្រាប់ថារូបខ្លួនត្រូវបានគេចាប់ ឬឃុំខ្លួនដោយសារមូលហេតុអ្វីនោះទេ។ លុះត្រាច្រើនម៉ោងរំលងផុតទៅ ទើបចុងចោទបានជួបជាមួយចៅក្រមស៊ើបអង្កេត ហើយត្រូវបានគេប្រាប់អំពីបទចោទប្រកាន់ប្រឆាំងមកលើខ្លួន។ ចុងចោទត្រូវបានបញ្ជូនភ្លាមៗទៅកាន់ពន្ធនាគារព្រៃស។

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវី ដែលជ្រើសរើសដោយខ្លួនឯង។

សេចក្តីពន្យល់ទូទៅលេខ១៣ របស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្នុងកថាខ័ណ្ឌ៩ ចែងថា ៖ «ជនជាប់ចោទត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយតបជាមួយមេធាវីដែលខ្លួនជ្រើសរើសដោយខ្លួនឯង។ អ្វីដែលកំណត់ថា "ពេលវេលាគ្រប់គ្រាន់" គឺអាស្រ័យលើស្ថានភាពរបស់ករណីនីមួយៗ ប៉ុន្តែសម្រាប់សម្ភារៈរូបវន្តវិញត្រូវតែរាប់បញ្ចូលនូវលទ្ធភាពទទួលបានឯកសារ និងភស្តុតាងដែលជនជាប់ចោទត្រូវការដើម្បីត្រៀមលក្ខណៈការពារក្តី ព្រមទាំងឱកាសក្នុងការឆ្លើយឆ្លងជាមួយមេធាវីរបស់ខ្លួន»។ សម្រាប់ករណីរឿងក្តីនេះ ចុងចោទមានពេលវេលាគ្រប់គ្រាន់ក្នុងការការពារក្តីរបស់ខ្លួនជាមួយនឹងមេធាវីដែលខ្លួនបានជ្រើសរើស។

(គ) ត្រូវបានជំនុំជម្រះដោយឥតពន្យាពេលយូរហួស

ចុងចោទត្រូវបានជំនុំជម្រះក្តី ប្រហែលជា៤ខែក្រោយពីការឃុំខ្លួន។ នេះអាចចាត់ទុកថាជាពេលវេលាមួយសមរម្យ។ ពាក់ព័ន្ធនឹងនិតិវិធីបណ្តឹងឧទ្ធរណ៍វិញ ករណីនេះប្រើពេលជាង៤ខែ សម្រាប់សាលាឧទ្ធរណ៍កំណត់កាលបរិច្ឆេទជំនុំជម្រះក្តីដែលត្រូវបានកំណត់ធ្វើនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ ខាងមុខនេះ។

(ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសដោយខ្លួនឯង

ខណៈពេលដែលចុងចោទមានវត្តមាននៅពេលជំនុំជម្រះ ហើយត្រូវបានគេអនុញ្ញាតឲ្យជ្រើសរើសមេធាវីដោយ

---

[21] ក្រុមប្រឹក្សាសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ «ទំនាក់ទំនងលេខ ២៤៨/១៩៨៧ លើករណី ជី ខេមប៊ែល និងចេមមៃកា ទំព័រ២៤៦ កថាខ័ណ្ឌទី៦.៣។

ផ្ទាល់ខ្លួនឯង ករណីនេះមិនបានកើតឡើងសម្រាប់បងប្អូនប្រុសទាំងពីរនាក់របស់ចុងចោទ ដែលត្រូវបានគេចោទប្រកាន់ និង កាត់ទោសស្របពេលជាមួយគ្នានោះ ដោយកំបាំងមុខ។ បើទោះបីជាការពិភាក្សាលើករណីចោទប្រកាន់ប្រឆាំងមកលើបុរសពីររូបនេះ ហួសពីវិសាលភាពនៃការវិភាគច្បាប់នេះក៏ដោយ អ្វីដែលសំខាន់គួរពិចារណាលើចំណុចនេះគឺទស្សនៈវិស័យរបស់ភស្តុតាង គឺថានេះជារឿងអកុសលដែលជនជាប់ចោទទាំងពីរមិនមានវត្តមានក្នុងសវនាការដើម្បីការពារប្រឆាំងបទចោទមកលើខ្លួន ហើយកិច្ចការពារខ្លួននេះអាចជួយសម្រួលដល់ករណីរបស់ចុងចោទផងដែរ។

ការធានាចុងក្រោយបីផ្សេងទៀតដែលមានចែងក្នុងមាត្រា ១៤(៣) នៃ ក.អ.ស.ព.ន នោះគឺ (ង) ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក (ច) ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ (ឆ) មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។ ក្នុងអំឡុងពេលអង្កេតការណ៍សវនាការ មិនរកឃើញថាមានការបំពានចំពោះបណ្ដាប្បញ្ញត្តិទាំងនេះទេ។

ឆ្លងកាត់តាមការវិភាគខាងលើ រាល់សិទ្ធិនិតិវិធីរបស់ចុងចោទ ដូចមានចែងក្នុងមាត្រា ១៤(៣)នៃ ក.អ.ស.ព.ន គឺត្រូវបានគេគោរពប្រតិបត្តិ ប៉ុន្តែការវិភាគក៏បានរកឃើញថា ការធានាចម្បងៗជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ពោលគឺសិទ្ធិទទួលបានការកាត់ក្ដីពីតុលាការអព្យាក្រិត និងសិទ្ធិសន្មត់ជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់ គឺត្រូវបានគេបំពាន ក្នុងករណីរឿងក្ដីនេះ។

## ៦. សេរីភាពមូលដ្ឋាន

ដោយយល់ឃើញនូវ (១) កង្វះភស្តុតាងគ្រប់គ្រាន់ផ្សារភ្ជាប់ចុងចោទទៅនឹងបទឧក្រិដ្ឋ (ដូចបានបង្ហាញក្នុងផ្នែកបទចោទ និងភស្តុតាងខាងលើ) (២) ការជាប់ពាក់ព័ន្ធរបស់ចុងចោទក្នុងករណីទាមទារសិទ្ធិដីធ្លីបឹងកក់ និងតួនាទីរបស់ចុងចោទជាអ្នកនាំពាក្យឲ្យសហគមន៍ (៣) អង្គហេតុដែលចុងចោទត្រូវបានអាជ្ញាធរមូលដ្ឋានគំរាមតាមរយៈពាក្យសំដី មុនពេលការចាប់ខ្លួនចុងចោទ (៤)ការប្រើប្រាស់តុលាការកន្លងមកក្នុងការបំបិទមាត់អ្នកភូមិបឹងកក់ និងសកម្មជនដីធ្លីដទៃទៀត (៥) អង្គហេតុដែលការកាត់ទោសប្រឆាំងមកលើរូបលោក លួស សាខន ត្រូវបានព្យួរ ខណៈដែលករណីរបស់ចុងចោទត្រូវបានបន្ត នេះធ្វើឲ្យបណ្ដាអង្គការជាតិ និងអន្តរជាតិ យល់ថា ចុងចោទត្រូវបានគេដៅមុខសញ្ញា ដោយសារតែការប្រើប្រាស់សិទ្ធិមូលដ្ឋានក្នុងការបញ្ចេញមតិ និងជួបប្រជុំជាដើម។ សេរីភាពជាមូលដ្ឋាននេះ ត្រូវបានការពារដោយច្បាប់ជាតិ និងអន្តរជាតិដូចកំណត់ខាងក្រោម។

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋទាំងអស់មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងជួបប្រជុំ។ មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញ បានចែងថា ពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិ ក្នុងការ "ចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"។ មាត្រា ៣១ បានចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសេចក្ដីប្រកាសជាសលកស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស ដែលក្នុងនោះរួមមាន ក.អ.ស.ព.នផងដែរ។ ក.អ.ស.ព.ន ក៏ត្រូវបានដាក់បញ្ចូលក្នុងច្បាប់ជាតិ តាមរយៈការផ្ដល់សច្ចាប័នរបស់ប្រទេសកម្ពុជាកាលពីឆ្នាំ១៩៩២ ដែលការដាក់បញ្ចូលនេះត្រូវបានបញ្ជាក់ដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលចែងថា «កតិកាសញ្ញាអន្តរជាតិទាំងឡាយដែលកម្ពុជាបានទទួលស្គាល់» នឹងត្រូវបញ្ចូលជាច្បាប់ជាតិ។[22] មាត្រា ១៩ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងក.អ.ស.ព.នចែងអំពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ពលរដ្ឋគ្រប់រូប ហើយមាត្រា ២០ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងក.អ.ស.ព.នក៏បានការពារដល់សិទ្ធិក្នុងការជួបប្រជុំផងដែរ។

ការចោទប្រកាន់ប្រឆាំងមកលើចុងចោទ ក៏ត្រូវបានគេជឿជាក់ថា គឺផ្សារភ្ជាប់នឹងសកម្មភាពរបស់ចុងចោទជាសកម្មជនការពារសិទ្ធិមនុស្ស និងការប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការការពារសិទ្ធិនានាដូចបានលើកខាងដើម។ ក្នុងនាទីជាអ្នកដឹកនាំ

[22] ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សេចក្ដីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

និងជាអ្នកនាំពាក្យឲ្យសហគមន៍របស់ខ្លួន ក្នុងអំឡុងពេលតវ៉ាប្រឆាំងនឹងការកាត់ទោសនិងដាក់ពន្ធនាគារចំពោះអ្នកភូមិបឹងកក់ទាំង១៣រូប ចុងចោទបានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការការពារសិទ្ធិមនុស្ស។ ចុងចោទបានការពារសិទ្ធិរបស់សហគមន៍ខ្លួនក្នុងការមានទីលំនៅសមរម្យ ដូចបានធានាក្រោមមាត្រា១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ក.អ.ស.ស.វ) ដែលកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ១៩៩២។[23] ជាងនេះទៀតនោះ ក្នុងការអំពាវនាវឲ្យមានការដោះលែងអ្នកភូមិទាំង១៣រូបនោះ ចុងចោទបានដើរតួការពារសិទ្ធិរបស់ពួកគាត់ក្នុងការចូលរួមក្នុងជីវភាពនយោបាយរបស់ប្រទេសជាំតិ ដូចបានធានាក្នុងមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ២៥ នៃក.អ.ស.ព.ន និងការពារដល់សិទ្ធិក្នុងការបញ្ចេញមតិ និងការប្រជុំ ដូចបានចែងក្នុងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៩ និងមាត្រា ២១ នៃក.អ.ស.ព.ន។[24] សេចក្តីប្រកាសរបស់អង្គសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស ដែលអនុម័តដោយមហាសន្និបាតកាលពីឆ្នាំ១៩៩៨ បើទោះជាមិនមានលក្ខណៈចងដោយច្បាប់ក៏ដោយ ក៏ឯកសារនេះគឺផ្អែកលើកម្រងសិទ្ធិ និងគោលការណ៍ជាច្រើនដែលមានចែងក្នុងលិខិតូបករណ៍អន្តរជាតិដទៃទៀត ដូចជាក.អ.ស.ព.ន ដែលត្រូវបានចងជាលក្ខណៈច្បាប់។ រដ្ឋភាគីជាច្រើនបានពិចារណានឹងអនុម័តសេចក្តីប្រកាសនេះ ជាច្បាប់ជាតិ បើទោះជាកម្ពុជាមិនទាន់បានបង្ហាញឆន្ទៈណាមួយក៏ដោយ។ ឯកសារនេះជាចលករដ៏មានប្រយោជន៍ ហើយជាអ្វីដែលអ្នកការពារសិទ្ធិមនុស្សក្នុងពិភពលោក អាចយោងជាខែលការពារដល់សកម្មភាពសិទ្ធិមនុស្សរបស់ពួកគេ។[25]

ការយាយីដោយប្រើអំណាចតុលាការប្រឆាំងលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា គឺត្រូវបានគេដឹងឮ និងសម្រាប់ករណីរឿងក្តីនេះ បើទោះបីជាការចោទប្រកាន់មិនបានពាក់ព័ន្ធដោយផ្ទាល់ចំពោះភាពសកម្មរបស់ចុងចោទក៏ដោយ កង្វះភស្តុតាងដើម្បីធានាដល់ការកាត់ទោស បានធ្វើឲ្យគេជឿជាក់ថា សកម្មភាពការងាររបស់ចុងចោទក្នុងនាមជាអ្នកការពារសិទ្ធិមនុស្សមួយរូប គឺជាមូលហេតុពិតប្រាកដដែលធ្វើឲ្យអាជ្ញាធរចាត់វិធានការលើករណីនេះ។ ជាការពិត ការចោទប្រកាន់អ្នកការពារសិទ្ធិមនុស្ស ឬសកម្មជនសិទ្ធិមនុស្ស អំពីបទល្មើសណាមួយដែលមិនពាក់ព័ន្ធដល់កិច្ចការងារផ្ទាល់របស់អ្នកទាំងនោះក្នុងនាមជាអ្នកការពារសិទ្ធិមនុស្សនោះ បានក្លាយជាឧបាយកលមួយដើម្បីសំដៅដល់អ្នកការពារសិទ្ធិមនុស្ស និងដើម្បីបង្វែរករណីរបស់ពួកគេពីអ្នកជួយគាំទ្រជាតិ និងអន្តរជាតិ។ ការដាក់ចុងចោទក្នុងពន្ធនាគារ ដោយសារតែការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួន គឺជាការបំពានដល់សិទ្ធមានសេរីភាពរបស់ចុងចោទ ដូចបានចែងក្នុងមាត្រា៩ នៃក.អ.ស.ព.ន។

## ៧. សេចក្តីសន្និដ្ឋាន

គោលបំណងនៃការវិភាគផ្នែកច្បាប់នេះ ធ្វើឡើងដើម្បីផ្តល់នូវការវិភាគមួយដោយឯករាជ្យ ជុំវិញបទចោទប្រឆាំងមកលើចុងចោទ ដោយផ្អែកតាមភស្តុតាងដែលបានលើកមកសំអាងក្នុងសវនាការ និងស្ថានការណ៍ជុំវិញករណីរឿងក្តីនេះ ។ សំណុំក្តីដែលតំណាងអយ្យការធ្វើការអះអាងឡើងនោះ គឺមានលក្ខណៈខ្សោយ ។ អំណះអំណាងរបស់សាក្សី គឺមិនមានភាព

---

[23] មាត្រា ១១ នៃក.អ.ស.ស.វ ចែងថា "រដ្ឋភាគីនៃកតិសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូបក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សំលៀកបំពាក់ និងទីលំនៅគ្រប់គ្រាន់ ព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ"។

[24] សូមមើលការវិភាគផ្នែកច្បាប់របស់ម.ស.ម.ក ស្តីពីការចោទប្រកាន់ និងកាត់ទោសអ្នកតំណាង១៣រូបរបស់សហគមន៍បឹងកក់ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ (ករណីព្រហ្មទណ្ឌលេខ ១៥៧៦/២៤.០៥.២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=19&id=5>

[25] បន្ថែមលើសនេះ នាពេលថ្មីៗនេះ កាលពីថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៣ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តជាឯកច្ឆន្ទក្នុងកិច្ចប្រជុំលើកទី២២របស់ខ្លួន នូវសេចក្តីសម្រេចមួយស្តីពីការការពារអ្នកការពារសិទ្ធិមនុស្ស ដែលអំពាវនាវដល់រដ្ឋភាគីទាំងអស់ឲ្យធានាថា "អ្នកការពារសិទ្ធិមនុស្សអាចបំពេញតួនាទីសំខាន់របស់ខ្លួន ក្នុងបរិបទការតវ៉ាដោយសន្តិវិធី ស្របតាមច្បាប់ជាតិ ដែលស៊ីសង្វាក់នឹងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិដទៃទៀត" (មាត្រា ៦) និងធានាថា "រាល់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនឹងមិនត្រូវបានគេដាក់ទោសទណ្ឌ ហើយអ្នកការពារសិទ្ធិមនុស្សនឹងមិនត្រូវបានគេទប់ស្កាត់ពីការប្រើប្រាស់សិទ្ធិមនុស្សជាសកលដើម្បីបំពេញការងាររបស់ពួកគេនោះទេ" (មាត្រា ១១(ក))។ "កិច្ចគាំពារអ្នកការពារសិទ្ធិមនុស្ស" (ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៣) គណៈប្រតិភូអចិន្ត្រៃយ៍នៃប្រទេសន័រវេស ប្រចាំទីក្រុងហ្សឺណែវ http://www.norway-geneva.org/PageFiles/648963/A%20HRC%2022%20L%2013%20FINAL%20VERSION.pdf

ស៊ីសង្វាក់គ្នា ហើយសក្ខីកម្មរបស់ជនរងគ្រោះដើមបណ្ដឹងគឺមិនអាចទុកចិត្តបាន ដោយសារថាពួកគេបានផឹកស្រាជាច្រើនម៉ោងមុននឹងព្រឹត្តការណ៍វាយប្រហារបានកើតឡើង ហើយពួកគេត្រូវបានអនុញ្ញាតឲ្យនៅក្នុងសាលសវនាការដើម្បីស្ដាប់រាល់សក្ខីកម្មរបស់សាក្សីដទៃទៀតដល់ចប់ ហើយពួកគេមិនត្រូវបានតម្រូវឲ្យធ្វើការស្បថស្បែនោះទេ។ ចុងចោទផ្ទាល់មិនបានស្គាល់សាក្សីដាក់បន្ទុកដែលបានផ្ដល់សក្ខីកម្មប្រឆាំងមកលើរូបខ្លួន ហើយក៏មិនស្គាល់ជនរងគ្រោះដើមបណ្ដឹងផងដែរ។ នេះពិតជាលំបាកឲ្យជឿ ដែលថាជនរងគ្រោះដើមបណ្ដឹងនោះ បានរស់នៅក្នុងតំបន់នោះនៅជិតបងប្អូនប្រុសរបស់ចុងចោទអស់រយៈពេល ៣ឆ្នាំ។ លើសនេះទៀត បងប្អូនប្រុសរបស់ចុងចោទ គឺលោក យ៉ោម សិទ្ធ និងលោក យ៉ោម កន្លង់ ត្រូវបានគេដឹងថា បានចាកចេញពីតំបន់នោះ ហើយបានផ្លាស់ទីលំនៅទៅរស់នៅកន្លែងផ្សេង។ អាស្រ័យហេតុនេះ មិនទំនងនោះទេ ដែលថាអ្នកទាំងពីរមានវត្តមាននៅទីកន្លែងកើតហេតុនោះ។ អង្គហេតុដែលថា ករណីទាំងមូលប្រឆាំងមកលើចុងចោទ គឺចងភ្ជាប់នឹងពិរុទ្ធភាពដែលគេអះអាងថា បងប្អូនប្រុសទាំងពីររបស់ចុងចោទបានប្រព្រឹត្តនោះ គឺរឹតតែមានបញ្ហាថែមទៀត ដោយសារថាពួកគាត់មិនមានវត្តមានក្នុងតុលាការ ដើម្បីអាចត្រូវបានសួរចម្លើយ ឬដើម្បីការពារខ្លួន។ ជាការពិតដែលកញ្ចក់រថយន្តរបស់ចុងចោទ ត្រូវបានគេលួចគាស់ ប៉ុន្តែចុងចោទបានរាយការណ៍ឧបទ្ទវហេតុនេះដល់ប៉ូលីសរួចហើយ ហើយចុងចោទមិនដឹងថាអ្នកណាគួរឲ្យសង្ស័យនោះដែរ។

ដោយយល់ឃើញនូវទិដ្ឋភាពសវតារនៃករណីរឿងក្ដីនេះ ពោលគឺអង្គហេតុដែលថាចុងចោទ ត្រូវបានគេគំរាមដោយសារទង្វើសកម្មរបស់ខ្លួន ហើយត្រូវបានប៉ូលីសប្រាប់ថា "ខ្លួននឹងប្រឈមនឹងបញ្ហានាពេលឆាប់ៗនោះ" ទង្វើចាប់ខ្លួនចុងចោទដោយប៉ូលីសបានល្បួងចុងចោទឲ្យចេញពីផ្ទះ ហើយក៏ច្រានចូលរថយន្តមួយដោយមិនប្រាប់អំពីមូលហេតុ ករណីប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សដទៃទៀតដែលបានប្រឈមនឹងការយាយីពីប្រព័ន្ធតុលាការ ដូចករណីរបស់អ្នកស្រី ទឹម សាក់មុន្នី ជាឧទាហរណ៍ ការព្យួរទោសលើករណីលោក លួស សាខន និងកង្វះភស្តុតាងដើម្បីដាក់បន្ទុកដល់ការកាត់ទោសចុងចោទ នេះបង្ហាញឲ្យឃើញថាមានកត្តាក្រៅអំពីច្បាប់ត្រូវបានជាប់ពាក់ព័ន្ធដល់ករណីនេះ។ ដោយសំអាងលើបទដ្ឋានច្បាប់សុទ្ធសាធករណីនេះគួរត្រូវបានតុលាការដែលប្រកាន់ច្បាប់មួយ ទម្លាក់ចោល។ បើក្រឡេកមើលតាមសេចក្ដីលម្អិតនៃករណីក្ដីនេះ តាមទស្សនៈវិស័យភស្តុតាង និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ យើងសង្កេតឃើញថា ចុងចោទត្រូវបានគេដៅមុខតាមរយៈការប្រើប្រាស់តុលាការពុករលួយ មិនមែនដោសារតែចុងចោទជាប់ពិរុទ្ធនៃការវាយប្រហារនោះទេ ប៉ុន្តែដោយសារតែចុងចោទមិនមានការខ្លាចរអារក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងបញ្ចេញមតិ និងការប្រជុំ ព្រមទាំងសិទ្ធិនានាផ្សេងៗទៀតក្នុងការការពារសិទ្ធិមនុស្ស។

ស្របតាមរឿងរ៉ាវដែលបានរៀបរាប់ដោយឯករាជ្យរួចមក នេះអាចសន្និដ្ឋានបានថា សាលាដំបូងរាជធានីភ្នំពេញមិនបានស្រាយបំភ្លឺមន្ទិលចំពោះការចោទថាចុងចោទមានពិរុទ្ធភាពក្នុងករណីហឹង្សាដោយចេតនានោះទេ ហើយសាលក្រមពិរុទ្ធភាពប្រឆាំងមកលើចុងចោទនោះគឺមិនសមហេតុផលផងដែរ។ អាស្រ័យហេតុនេះហើយ សាលាឧទ្ធរណ៍គួរធ្វើសវនាការចំពោះរឿងក្ដីរបស់ចុងចោទ ជាបន្ទាន់ ហើយគួរផ្ដល់ក្ដីសម្រេចមួយដោយឈរលើមូលដ្ឋានទឡ្ហីករណ៍ និងច្បាប់តែម្យ៉ាងគត់ដោយមិនអនុញ្ញាតឲ្យមានការជះឥទ្ធិពលពីខាងក្រៅបាននោះឡើយ។ ផ្អែកតាមការវិភាគលើបទចោទ និងភស្តុតាងខាងលើប្រសិនបើចុងចោទបានទទួលនូវការជំនុំជម្រះពីសាលាឧទ្ធរណ៍ដែលយុត្តិធម៌ និងឯករាជ្យ នោះសាលក្រមពិរុទ្ធភាពរបស់ចុងចោទនឹងត្រូវបានច្រានចោលជាមិនខាន៕